**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ០៣.សរណន

# សារាចរណែនាំ

## ស្តីពី

## ការរៀបចំខួបលើកទី ៥៨ "ទិវាកុមារអន្តរជាតិ ១ មិថុនា " និងខួបលើកទី ៦ "ទិវាពិភពលោកប្រឆាំងនឹងពលកម្មកុមារ ១២ មិថុនា " ឆ្នាំ ២០០៧

ក្នុងអំឡុងឆ្នាំ ១៩៤២-១៩៤៤ នៃសង្គ្រាមលោកលើកទី២ ពួកហ្វាស៊ីសអ៊ីត្លែរបានបង្កវិនាសកម្មកាប់សម្លាប់ស្ត្រី និងកុមារនៅភូមិលីឌីសែ ប្រទេសឆេក និងភូមិអូរ៉ាឌី ប្រទេសបារាំង។ វិនាសកម្មនេះធ្វើឱ្យ ប្រជាជនក្នុងពិភពលោកឈឺចាប់យ៉ាងខ្លាំង ជំរុញឱ្យប្រទេសជាច្រើនលើពិភពលោក កំណត់យកថ្ងៃទី ១ មិថុនា នេះជាទិវាកុមារអន្តរជាតិ។ ដោយឡែកការប្រើប្រាស់ពលកម្មកុមារក្នុងទម្រង់ធ្ងន់ធ្ងរ បានកើតមានក្នុងចំណោមកុមារប្រមាណជាង ១០០ លាននាក់ អាយុពី ៥ឆ្នាំ ដល់១៧ ឆ្នាំ។ ទម្រង់ដ៏អាក្រក់នោះ មាន ទាសករកុមារ ការជួញដូរកុមារ ពេស្យាចារកុមារ កុមារក្នុងជម្លោះប្រដាប់អាវុធ និងការប្រើប្រាស់កុមារក្នុងស្ថានភាព ងាយរងគ្រោះ។ ហេតុនេះហើយ បានជាអង្គភាពពលកម្មកុមារអន្តរជាតិ បានសម្រេចយកថ្ងៃ ១២ មិថុនា ជារៀងរាល់ឆ្នាំ ដើម្បីរំលឹកទិវាពិភពលោកប្រឆាំងនឹងពលកម្មកុមារ។

ព្រះរាជាណាចក្រកម្ពុជាធ្លាប់បានជួបប្រទះ និងបានទទួលរងមហាវិនាសកម្មដ៏ធ្ងន់ធ្ងរ បង្កឡើងដោយរបបប្រល័យពូជសាសន៍ប៉ុល ពត ដែលបានធ្វើឱ្យប្រជាជន យុវជន កុមារ បាត់បង់សិទ្ធិជាមនុស្ស ត្រូវបានបង្ខំឱ្យធ្វើការជាទម្ងន់ រស់នៅយ៉ាងសែនវេទនា រងទូវទារុណកម្ម និងការកាប់សម្លាប់ដោយអយុត្តិធម៌អស់រាប់លាននាក់។ ក្រោយ ថ្ងៃរំដោះ ៧ មករា ឆ្នាំ ១៩៧៩ សិទ្ធិរបស់ប្រជាពលរដ្ឋ ជាពិសេស សិទ្ធិរបស់កុមារនៅកម្ពុជា ត្រូវបានរាជរដ្ឋាភិបាលយកចិត្តទុកដាក់ ដោយមានចែងច្បាស់ក្នុងរដ្ឋធម្មនុញ្ញ និងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលស្របទៅតាមអនុសញ្ញាអន្តរជាតិផ្សេងៗដែលពាក់ព័ន្ធនឹងកុមារ។ ព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញា ស្តីពីសិទ្ធិកុមារ នៅថ្ងៃទី ១៥ ខែតុលា ឆ្នាំ ១៩៩២ និងនៅឆ្នាំ ២០០២ បានផ្តល់សច្ចាប័នលើពិធីសារពីរ គឺ : មួយៈ ការចូលរួមរបស់កុមារក្នុងជម្លោះប្រដាប់អាវុធ ពីរ : ការជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារ និងការផ្សព្វផ្សាយរូបភាពអាសអាភាសរបស់កុមារ ។ នៅឆ្នាំ ២០០៣ រាជរដ្ឋាភិបាលបានចេញសេចក្តីថ្លែងការណ៍ស្តីពីកម្ពុជាដើម្បីកុមារ និងនៅឆ្នាំ ២០០៥ ព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាលេខ ១៨២ ស្តីពីការហាមប្រាម និងសកម្មភាពបន្ទាន់សម្រាប់ការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុត នៃពលកម្មកុមារ ហើយនៅពេលកន្លងមកថ្មីៗនេះ បានផ្តល់សច្ចាប័នលើអនុសញ្ញាក្រុងឡាអេ ស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស។ ទន្ទឹមនេះ ព្រះរាជាណាចក្រកម្ពុជាក៏បានចុះកិច្ចព្រមព្រៀងជាមួយប្រទេសវៀតណាម

ប្រទេសថៃឡង់ដ៏ និងបណ្តាប្រទេសមហាអនុតំបន់ទន្លេមេគង្គ ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគី ពហុភាគី ក្នុងការលុបបំបាត់ការជួញដូរកុមារ និងស្ត្រី និងជួយជនរងគ្រោះ ។

ក្នុងស្មារតីបង្កើនសកម្មភាព នៃកិច្ចគាំទ្រ និងការពារដល់កុមារ ដើម្បីអនុវត្តឱ្យបានកាន់តែប្រសើរឡើង ថែមទៀតនូវសិទ្ធិចម្បងទាំង ០៤ របស់កុមារ គឺសិទ្ធិរស់រានមានជីវិត សិទ្ធិទទួលបានការការពារ សិទ្ធិក្នុងការអភិវឌ្ឍ និងសិទ្ធិក្នុងការចូលរួម និងដើម្បីលើកស្ទួយឧត្តមប្រយោជន៍របស់កុមារ រាជរដ្ឋាភិបាលណែនាំចាត់តាំងទិវាកុមារអន្តរជាតិ ១ មិថុនា និងទិវាពិភពលោកប្រឆាំងនឹងពលកម្មកុមារ ១២ មិថុនា ឆ្នាំ ២០០៧ ដូចខាងក្រោម :

១-ប្រធានបទនៃទិវាកុមារអន្តរជាតិ ១ មិថុនា ឆ្នាំនេះគឺ "**យើងរួមគ្នាលុបបំបាត់អំពើហិង្សាលើកុមារ** "។

២-គ្រប់ក្រសួង ស្ថាប័ន ខេត្ត ក្រុង និងអាជ្ញាធរមានសមត្ថកិច្ចគ្រប់ថ្នាក់ ត្រូវធ្វើកិច្ចសហការគ្នាជាមួយអង្គការជាតិ អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល ផ្នែកឯកជន និងប្រជាពលរដ្ឋ ដើម្បីឧបត្ថម្ភគាំទ្រ និងផ្សព្វផ្សាយជូនដល់អង្គភាពក្រោមឱវាទ និងសង្គមជាតិទាំងមូលឱ្យបានជ្រួតជ្រាប អំពីប្រវត្តិនៃទិវាកុមារ អន្តរជាតិ ១ មិថុនា និងទិវាពិភពលោកប្រឆាំងនឹងពលកម្មកុមារ ១២ មិថុនា។

៣-គ្រប់ក្រសួង ស្ថាប័ន និងអាជ្ញាធរដែនដីខេត្ត ក្រុង ត្រូវរៀបចំពិធីមីទិញ ឬពិធីជួបសំណេះសំណាលជាមួយកុមារ និងមានកម្មវិធីកំសាន្តសប្បាយរបស់កុមារ នៅក្នុងមូលដ្ឋានរបស់ខ្លួនតាមលទ្ធភាព ជាក់ស្តែង ។

៤-ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ អន្តរជាតិ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល ក្រសួងព័ត៌មាន ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ សាលាក្រុងភ្នំពេញ និងស្ថាប័នពាក់ព័ន្ធ ត្រូវសហការរៀបចំមីទិញ និងមានកម្មវិធីកំសាន្តផ្សេងៗ សម្រាប់កុមារនៅទីសាធារណៈ ឬរមណីយដ្ឋានណាមួយ សមស្របនៅរាជធានីភ្នំពេញ ឱ្យបានអធិកអធម ។

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ត្រូវសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីត្រៀមថវិកាសម្រាប់ការរៀបចំពិធីនេះ ។

ទទួលបានសារាចរណែនាំនេះ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដីគ្រប់ខេត្ត ក្រុង ត្រូវរៀបចំចាត់តាំងអនុវត្តឱ្យបានប្រកបដោយស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធភាពខ្ពស់ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-គ្រប់ក្រសួង ស្ថាប័ន
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-សាលាខេត្ត ក្រុង
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ